**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៥៤៦ ប្រក. កសក

# ប្រកាស

## ស្តីពី

## ការធ្វើវិញ្ញាបនកម្មច្បារពូជកៅស៊ូ និងការធ្វើអាជីវកម្មរុក្ខសម្ភារកៅស៊ូ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៥ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និង សិទ្ធិអ្នកបង្កាត់ពូជដំណាំ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក.ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៧ ស្តីពីការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ

១

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨/៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០

- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្ដីពីការត្រួតពិនិត្យភូតគាមអនាម័យ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**ប្រការ ១ :** ប្រកាសនេះមានគោលដៅដាក់បញ្ញត្តិ និងលក្ខខណ្ឌតិយុត្តក្នុងការគ្រប់គ្រង នាំចេញនាំចូល ចែកចាយរុក្ខសម្ភារកៅស៊ូ និងការធ្វើវិញ្ញាបនកម្មថ្នាលពូជកៅស៊ូនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២ :** ប្រកាសនេះមានគោលបំណង ÷

- ធានានិរន្តរភាពក្នុងការអភិរក្សភាពត្រឹមត្រូវនៃក្លូនកៅស៊ូ
- ធានាការផ្គត់ផ្គង់មែកពូជនៃក្លូនកៅស៊ូដែលចេញពីថ្នាលពូជដែលបានទទួលស្គាល់ដោយវិទ្យាស្ថាន
- បង្កើនផលិតភាពដំណាំកៅស៊ូប្រកបដោយប្រសិទ្ធភាពសេដ្ឋកិច្ច
- ទប់ស្កាត់ការក្លែងបន្លំក្លូនកៅស៊ូ និងលុបបំបាត់ការធ្វើអាជីវកម្មផ្គត់ផ្គង់ក្លូនកៅស៊ូដែលគ្មានគុណភាពសេនេទិច
- ផ្ដល់ទំនុកចិត្តដល់អ្នកដាំកៅស៊ូក្នុងការវិនិយោគអភិវឌ្ឍន៍ដំណាំកៅស៊ូ និងផលិតកម្មកៅស៊ូ។

**ប្រការ ៣ :** វាក្យស័ព្ទគន្លឹះដែលប្រើនៅក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម ÷

- "វិញ្ញាបនកម្មថ្នាលពូជកៅស៊ូ" សំដៅដល់ការចេញវិញ្ញាបនបត្រថ្នាលពូជកៅស៊ូដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- "ថ្នាលពូជកៅស៊ូ" សំដៅដល់កន្លែងផលិតមែកពូជកៅស៊ូ សម្រាប់យកភ្នែកទៅបំបៅ
- "មែកពូជកៅស៊ូ" សំដៅដល់មែកពូជ ដែលកាត់ចេញពីដើមពូជនៅក្នុងថ្នាលពូជកៅស៊ូ និងមានភ្នែកសុទ្ធល្អសម្រាប់យកទៅបំបៅ
- "ក្លូនកៅស៊ូ" សំដៅដល់ដើមកៅស៊ូដែលមានអត្តសញ្ញាណដូចដើមមេ ដែលបង្កើតឡើងតាមការបន្តពូជដោយសរីរាង្គលូតលាស់ ឬដោយកោសិកា
- "កូនកៅស៊ូស៊ីដលីង" សំដៅដល់កូនកៅស៊ូដែលដាំដោយគ្រាប់មិនបានបំបៅ
- "រុក្ខសម្ភារកៅស៊ូ" សំដៅដល់គ្រាប់កៅស៊ូ កូនកៅស៊ូស៊ីដលីង កូនកៅស៊ូបំបៅ និងកំណាត់សរីរាង្គដើមកៅស៊ូ សម្រាប់យកទៅដាំ
- "វិទ្យាស្ថាន" សំដៅដល់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
- "ភ្នាក់ងារ" សំដៅដល់មន្ត្រីរបស់វិទ្យាស្ថានដែលបានចាត់តាំងឱ្យទៅបំពេញការងារត្រួតពិនិត្យនិងវាយតម្លៃថ្នាលពូជកៅស៊ូ

២

- "អនុសាសន៍ក្លូន" សំដៅដល់បញ្ជីថ្នាក់ក្លូនកៅស៊ូដែលណែនាំដោយវិទ្យាស្ថាន សម្រាប់រយៈពេលពីពីរទៅប្រាំឆ្នាំ ដោយផ្អែកលើលទ្ធផលនៃការពិសោធស្រាវជ្រាវរបស់វិទ្យាស្ថាន ។

**ប្រការ ៤ :** ក្នុងការគ្រប់គ្រង និងការធ្វើវិញ្ញាបនកម្មច្បារពូជកៅស៊ូ វិទ្យាស្ថានមានសមត្ថកិច្ច និងបំពេញមុខងារដូចខាងក្រោម ÷

- ធានានិរន្តរភាពនៃក្លូនកៅស៊ូប្រកបដោយគុណភាព សម្រាប់ផលិតកម្មកៅស៊ូនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- តាមដានត្រួតពិនិត្យ និងណែនាំដល់ម្ចាស់ច្បារពូជកៅស៊ូនៅទូទាំងប្រទេសឱ្យអនុវត្តស្របតាមសេចក្ដីណែនាំបច្ចេកទេស អំពីច្បារពូជកៅស៊ូរបស់វិទ្យាស្ថាន
- កំណត់អត្តសញ្ញាណក្លូនកៅស៊ូ
- វាយតម្លៃច្បារពូជកៅស៊ូ និងផ្ដល់វិញ្ញាបនបត្រច្បារពូជកៅស៊ូ
- សម្របសម្រួលការនាំចេញ នាំចូលរុក្ខសម្ភារកៅស៊ូ
- ធ្វើរបាយការណ៍ស្ដីពីលទ្ធផលដែលសម្រេចបានជូនស្ថាប័នអាណាព្យាបាល ។

**ប្រការ ៥ :** វិទ្យាស្ថានអាចផ្ដល់វិញ្ញាបនបត្រច្បារពូជកៅស៊ូចំពោះតែច្បារពូជកៅស៊ូទាំងឡាយណាដែលក្លូនកៅស៊ូមានឈ្មោះនៅក្នុងអនុសាសន៍ក្លូនរបស់វិទ្យាស្ថាន ឬជាក្លូនដែលមានការអនុញ្ញាតឱ្យនាំចូលពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សម្រាប់ការសាកល្បង ស្រាវជ្រាវ ។

ច្បារពូជកៅស៊ូដែលធ្វើអាជីវកម្ម ផ្គត់ផ្គង់ ប្រើប្រាស់ ឬបែងចែកមែកពូជបាន លុះត្រាតែច្បារពូជនោះត្រូវបានត្រួតពិនិត្យនិងវាយតម្លៃដោយភ្នាក់ងារ និងមានវិញ្ញាបនបត្រច្បារពូជកៅស៊ូដែលចេញដោយវិទ្យាស្ថាន ។

ច្បារពូជកៅស៊ូត្រូវបានត្រួតពិនិត្យនិងវាយតម្លៃដើម្បីទទួលបានវិញ្ញាបនបត្រ លុះត្រា ÷

- មានចំនួនគល់យ៉ាងតិច ២០០ (ពីររយ) គល់ ក្នុងក្លូននីមួយៗ
- មានក្លូនសុទ្ធល្អ
- ក្លូននីមួយៗ ត្រូវដាំជាប្លុកដាច់ដោយឡែកពីគ្នា
- មិនមានដំណាំដទៃដាំឆ្លូកជាមួយ ។

**ប្រការ ៦ :** វិញ្ញាបនបត្រច្បារពូជកៅស៊ូ មានសុពលភាពសម្រាប់រយៈពេល ០២ (ពីរ) ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្រ ។ ម្ចាស់ច្បារពូជ ត្រូវដាក់ពាក្យសុំវិញ្ញាបនបត្រច្បារពូជកៅស៊ូឡើងវិញរយៈពេល ០២ (ពីរ) ខែ មុនផុតកំណត់ ។

ការផ្លាស់ប្ដូរទីតាំង ការពង្រីកច្បារពូជបន្ថែម ឬការផ្ទេរសិទ្ធិគ្រប់គ្រងច្បារពូជដែលមានវិញ្ញាបនកម្មត្រូវសុំការអនុញ្ញាតជាមុនពីវិទ្យាស្ថាន ។

៣

**ប្រការ ៧ :** រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កើតច្បារពូជកៅស៊ូ ត្រូវស្នើសុំវិញ្ញាបនបត្រច្បារពូជកៅស៊ូនៅវិទ្យាស្ថាន។

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កើតច្បារពូជកៅស៊ូ ត្រូវមានជំនាញយ៉ាងទាបបំផុតត្រឹមថ្នាក់បឋមភ្យេគ្រសាស្ត្រ ឬ ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកដំណាំកៅស៊ូ ដោយមានសញ្ញាបត្រ ឬ វិញ្ញាបនបត្រ។ ម្ចាស់ច្បារពូជត្រូវទទួលខុសត្រូវចំពោះមុខច្បាប់លើគ្រប់សកម្មភាពនៃច្បារពូជ និងអ្នកប្រើប្រាស់។

**ប្រការ ៨ :** ការស្នើសុំវិញ្ញាបនបត្រច្បារពូជកៅស៊ូ ត្រូវបំពេញសំណុំបែបបទ និងភ្ជាប់មកជាមួយនូវលិខិតដូចខាងក្រោម ÷

១- ពាក្យស្នើសុំវិញ្ញាបនបត្រច្បារពូជកៅស៊ូមានបិទតែមប្រ៊ើ "មានគំរូ" ០១ច្បាប់។

២- កិច្ចសន្យាស្តីពី ការស្នើសុំវិញ្ញាបនបត្រច្បារពូជកៅស៊ូ "មានគំរូ" ០១ច្បាប់។

៣- ប្រវត្តិរូបសង្ខេបរបស់អ្នកស្នើសុំ "មានគំរូ" ០១ច្បាប់។

៤- គំនូរប្លង់ច្បារពូជ។

៥- លិខិតប្រគល់សិទ្ធិ។

៦- សញ្ញាបត្រ ឬវិញ្ញាបនបត្រច្បាប់ចម្លង ចូលរួមវគ្គបណ្តុះបណ្តាលដំណាំកៅស៊ូ។

ម្ចាស់ច្បារពូជ ត្រូវបញ្ជូនសំណុំបែបបទមកវិទ្យាស្ថាន។ ក្រោយពេលទទួលបានពាក្យស្នើសុំ វិទ្យាស្ថានត្រូវចាត់ភ្នាក់ងារចុះធ្វើការត្រួតពិនិត្យនិងវាយតម្លៃផ្ទាល់នៅច្បារពូជ។ នីតិវិធីដែលត្រូវត្រួតពិនិត្យនិងវាយតម្លៃមានដូចខាងក្រោម ÷

១- ភាពត្រឹមត្រូវនៃក្លូននីមួយៗ

- គិនភាគខាងក្រៅនៃក្លូននីមួយៗនៅគ្រប់គល់ដោយពិនិត្យមើលផ្ទាល់នឹងភ្នែក
- ក្នុងករណីសង្ស័យ ត្រូវយកសំណាកមកធ្វើការវិភាគនៅមន្ទីរពិសោធន៍។

២- ស្ថានភាពថែទាំ

- អនុវត្តតាមការណែនាំបច្ចេកទេសធ្វើច្បារពូជរបស់វិទ្យាស្ថាន។

ការផ្តល់វិញ្ញាបនបត្រច្បារពូជ ត្រូវផ្អែកលើសលាកបត្រត្រួតពិនិត្យនិងវាយតម្លៃ ។

**ប្រការ ៩ :** រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលនាំចេញ នាំចូលវត្ថុសម្ភារកៅស៊ូ ទោះជាសម្រាប់ពិសោធន៍សាកល្បងត្រូវមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

ការផ្ទេរសិទ្ធិទៅឱ្យបុគ្គលដទៃនូវលិខិតអនុញ្ញាតនាំចេញ នាំចូលវត្ថុសម្ភារកៅស៊ូ ត្រូវមានការយល់ព្រមជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

៤

**ប្រការ ១០ :** រាល់វត្ថុសម្ភារកៅស៊ូដែលធ្វើការនាំចេញ នាំចូល និងឆ្លងកាត់ ត្រូវមានវិញ្ញាបនបត្របញ្ជាក់ភូតគាមអនាម័យ និងវិញ្ញាបនបត្របញ្ជាក់ប្រភពដើមដែលផ្ដល់ដោយភ្នាក់ងារមានសមត្ថកិច្ច។

**ប្រការ ១១ :** រូបវន្តបុគ្គល ឬ នីតិបុគ្គលទាំងឡាយណាដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោម ÷

- ព្រមានជាលាយល័ក្ខណ៍អក្សរ និងតម្រូវឱ្យធ្វើកិច្ចសន្យាកែតម្រូវ
- ព្យួរ ឬដកហូតវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត
- ក្នុងករណីមិនរាងចាល ឬប្រព្រឹត្តល្មើសធ្ងន់ធ្ងរ នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**ប្រការ ១២ :** រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលបានបង្កើតច្បារពូជកៅស៊ូនៅមុនពេលប្រកាសនេះចូលជាធរមាន និងកំពុងធ្វើអាជីវកម្មកូនកៅស៊ូនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានលិខិតអនុញ្ញាត ឬមានលិខិតអនុញ្ញាតក្រោមនីតិវិធីផ្សេងពីប្រកាសនេះ ត្រូវស្នើសុំវិញ្ញាបនបត្រច្បារពូជកៅស៊ូអនុលោមតាមបទប្បញ្ញត្តិនៃប្រកាសនេះ ក្នុងរយៈពេលមិនលើសពី ៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះចូលជាធរមាន។

**ប្រការ ១៣ :** ប្រកាស ឬសេចក្ដីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ១៤ :** អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ នាយកខុទ្ទកាល័យ នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០

រដ្ឋមន្ត្រី

ច័ន្ទ សារុន

**កន្លែងទទួល :**

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-ក្រសួង ស្ថាប័នពាក់ព័ន្ធ

-ដូចប្រការ ១៤

-ឯកសារ-កាលប្បវត្តិ

៥